00589653

E188/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 08 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 08 / 2010
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខ**
**ប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង**
**ក្នុងករណីរឿង កាំង ហ្កេកអ៊ាវ *ហៅ* ឌុច**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម C.N.JAYASIINGHE
ចៅក្រម យ៉ា ណារិន

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:
លោក គង់ ពិសី
លោក ហុង គីមសួន
លោក យុង ផានិត
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
កញ្ញា SILKE Studzinsky
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី ទី ស្រ៊ីនណា

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ*

**ជនជាប់ចោទ:**
**កាំង ហ្គេកអ៊ាវ *ហៅ* ឌុច**

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

លោក Pierre-Olivier SUR
លោក Alain WERNER
លោក Brianne McGONIGLE
លោកស្រី Annie DELAHAIE
លោកស្រី Elizabeth RABESANDRATANA
លោក Karim KHAN
លោកស្រី Fabienne TRUSSES-NAPROUS

# សេចក្ដីផ្ដើម

១. សហព្រះរាជអាជ្ញា ដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខនេះ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រម")[1] ដែលបានផ្ដន្ទាទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ឱ្យមានទោសពីបទអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដូចដែលបានរៀបរាប់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ និងពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលផ្ដន្ទាទោសរូបគាត់ដាក់ពន្ធនាគារ ចំនួនសាមសិបប្រាំ (៣៥) ឆ្នាំ[2] ។

# ទឡ្ហីករណ៍ក្នុងការប្ដឹងសាទុក្ខ

២. ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ក្នុងការប្ដឹងសាទុក្ខ អំពីការភាន់ច្រឡំអង្គច្បាប់មួយចំនួនដែលធ្វើឱ្យសាលក្រមមិនអាចយកជាការបាន ដូចបានចែងនៅក្នុងកថាខណ្ឌខាងក្រោម[3] ។

## I. ទឡ្ហីករណ៍ទីមួយ: ការភាន់ច្រឡំដែលអាចឱ្យគេយល់បាន នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិក្នុងការផ្ដន្ទាទោស

៣. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយមានការភាន់ច្រលំនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមរយៈ៖

ក. ការផ្ដល់ទម្ងន់មិនគ្រប់គ្រាន់ទៅលើស្ថានទម្ងន់ទោសនៃ"ឧក្រិដ្ឋកម្មនានា"ដែលមានលក្ខណៈដ៏គួរឱ្យព្រឺខ្លាច និងដ៏សាហាវឃោរឃៅជាពិសេស" ដែលបានប្រព្រឹត្តឡើងដោយ ឌុច[4], តួនាទី និងចេតនាក្នុងការចូលរួមប្រព្រឹត្តរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មទាំងនោះ និង[5]ស្ថានទម្ងន់ផ្សេងៗទៀត[6]។

ខ. ការផ្ដល់ស្ថានសម្រាលហួសហេតុពេក[7] ។

---

[1] សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ: E188 ("សាលក្រម"), ទំព័រទី៦៧៧, ៦៧៩ ។

[2] វិធានផ្ទៃក្នុង, ច្បាប់វិសោធនកម្មលើកទី៥, ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០, ("វិធាន") ១០៥.៣, ១០៦.២, ១០៧.៤ ។

[3] វិធាន១០៥.៣, វិធានផ្ទៃក្នុង ។

[4] សាលក្រម, កថាខណ្ឌទី៥៩៦-៥៩៨, ៦០០ ។

[5] សាលក្រម, កថាខណ្ឌទី៥៩៧, ៥៩៩ ។

[6] សាលក្រម, កថាខណ្ឌទី៦០១-៦០៥, ៦៣០ ។

[7] សាលក្រម, កថាខណ្ឌទី៦០៨-៦១១, ៦២៩ ។

៤. ជាការបន្ថែម អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយភាន់ច្រឡំអង្គច្បាប់ ធ្វើឱ្យសាលក្រមមិនអាចយកជាការបាន តាមរយៈការខកខានមិនបានពិចារណាទៅលើច្បាប់អន្តរជាតិស្តីពីការផ្តន្ទាទោសដែលពាក់ព័ន្ធ និងអំពីរយៈពេលកំណត់ការផ្តន្ទាទោសមានស្រាប់ ដែលខ្លួនអាចរកបាននៅក្នុងករណីនានាដែលស្រដៀងគ្នានឹងករណីនេះ[8] ។ សហព្រះរាជអាជ្ញា សូមដាក់ជូនសេចក្តីសន្និដ្ឋានថា ទោសដែលបានដាក់ទៅលើ ឌុច គឺជាការធ្វើតាមទំនើងចិត្តនិងបង្ហាញយ៉ាងច្បាស់ណាស់ថាមានលក្ខណៈមិនទាន់គ្រប់គ្រាន់ទេ និងស្ថិតនៅក្រៅទំហំទោសដែលមានស្រាប់សម្រាប់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងកាលៈទេសៈបែបនេះ" ។

## II. ទឡ្ហីករណ៍ទីពីរ: ការភាន់ច្រឡំផ្នែកអង្គច្បាប់ស្តីពីការផ្តន្ទាទោសត្រួត

### *ក. ការធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដទៃទៀត*

៥. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោយភាន់ច្រឡំអង្គច្បាប់ ធ្វើឱ្យសាលក្រមមិនអាចយកជាការបាន ដោយសារការខកខានមិនបានកាត់ទោស ឌុច ឱ្យមានទោសត្រួតគ្នាពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលស្ថិតនៅក្នុងបទល្មើស ការធ្វើឱ្យទៅជាទាសករ, ការដាក់នៅក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការរំលោភសេពសន្ថវៈ, ការសម្លាប់រង្គាល (ដែលស្របទោសចូលនៅក្នុងបទល្មើសការធ្វើមនុស្សឃាត) និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយធ្វើការស្របទោសនៃឧក្រិដ្ឋកម្មទាំងនោះបញ្ចូលទៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយទៅវិញ[9] ។

### *ខ. ការធ្វើទារុណកម្ម និង ការរំលោភផ្លូវភេទ*

៦. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយភាន់ច្រលំនៅក្នុងអង្គច្បាប់ធ្វើអោយសាលក្រមមិនអាចយកជាការបាន ដោយការកំណត់ថា ការរំលោភផ្លូវភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាការធ្វើទារុណកម្មទៅវិញ និងតាមរយៈការខកខានមិនបានផ្តន្ទាទោស ឌុច ឱ្យមានទោសត្រួតគ្នាចំពោះបទរំលោភផ្លូវភេទ និងការធ្វើទារុណកម្មនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិផ្សេងៗគ្នា[10] ។

## III. ទឡ្ហីករណ៍ទីបី: ការភាន់ច្រឡំនៅក្នុងផ្នែកច្បាប់ទាក់ទងនឹងការធ្វើឱ្យទៅជាទាសករ

[8] ដីកាសន្និដ្ឋានបញ្ចប់សវនាការជេញដោល របស់សហព្រះរាជអាជ្ញា *សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, ការិយាល័យសហព្រះរាជអាជ្ញា, ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩, ឯកសារលេខ:* E159/9, *ការផ្តន្ទាទោស ជាទូទៅ និងកថាខណ្ឌទី ៤៥៣-៤៥៦ ជាពិសេស ។*

[9] សាលក្រម, កថាខណ្ឌទី ៥៦៣-៥៦៦, ៥៦៨, ៦៧៧ ។

[10] សាលក្រម, កថាខណ្ឌទី ២៤៦, ៣៦៦, ៦៧៧ ។

៧. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោយភាន់ច្រឡំនៅក្នុងអង្គច្បាប់ ដោយបានធ្វើឱ្យសាលក្រមមិនអាចទទួលយកជាការបាន តាមរយៈការប្រើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីបទការធ្វើឱ្យទៅជាទាសករ ដែលតម្រូវឱ្យមានការធ្វើពលកម្មដោយបង្ខំថាជាធាតុផ្សំដ៏សំខាន់មួយនៃការធ្វើឱ្យទៅជាទាសករទៅវិញ ។ នេះមិនមែនជាច្បាប់ត្រឹមត្រូវទេ តាមពិតគ្មានលក្ខខណ្ឌតម្រូវដូច្នេះទេ ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង មានកំហុសតាមរយៈការខកខានមិនបានផ្តន្ទាទោស ឌុច ពីការធ្វើឱ្យទៅជាទាសករទៅលើពួកជាប់ឃុំឃាំងនៅក្នុងមន្ទីរស២១ ដែលពួកទាំងនេះមិនត្រូវបានគេដាក់ឱ្យឋិតនៅក្រោមពលកម្មដោយបង្ខំនោះទេ[11] ។

## សេចក្តីសន្និដ្ឋាន

១០. សហព្រះរាជអាជ្ញា នឹងដាក់ជូនសារណានៃបណ្តឹងសាទុក្ខ នៅក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ បន្ទាប់ពីការដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខនេះ[12] ។ បណ្តឹងសាទុក្ខនេះ ស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល ទី១) កែតម្រូវលើការភាន់ច្រឡំក្នុងអង្គច្បាប់ និងទន្ទឹមនឹងនេះ ទី២) បង្កើនការផ្តន្ទាទោស ឌុច ថែមពីលើទោសដែលបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ | **លោកស្រី ជា លាង**<br>**សហព្រះរាជអាជ្ញា** | | |
| | **លោក Andrew CAYLEY**<br>**សហព្រះរាជអាជ្ញា** | | |

[11] សាលក្រម, កថាខណ្ឌទី ៣៤២-៣៤៦, ៦៧៧ ។

[12] វិធាន ១០៧.៤ នៃវិធានផ្ទៃក្នុង ។